គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា
Committee for Free and Fair Elections in Cambodia
ខុមហ្វ្រែល COMFREL

Vision: A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

ទស្សនៈវិស័យ ៖ ដើម្បីការបោះឆ្នោតមានអត្ថន័យ ដែលប្រកបដោយប្រយោជន៍ប្រជាពលរដ្ឋ

# សេចក្តីជូនដំណឹង

គណៈកម្មាធិការខុមហ្វ្រែល មានកិត្តិយសសូមជម្រាបជូនដំណឹងដល់លោក លោកស្រី នាងកញ្ញា តំណាងសារព័ត៌មាន វិទ្យុ ទូរទស្សន៍ជាតិ អន្តរជាតិ ព្រមទាំងអង្គការជាតិ និងអន្តរជាតិទាំងអស់ មេត្តាជ្រាបថា ដោយមានការឧបត្ថម្ភមូលនិធិពីសហភាពអឺរ៉ុប (EU), OXFAM NOVIB, NPA និង Forum Syd គណៈកម្មាធិការ ខុមហ្វ្រែល នឹងរៀបចំសិក្ខាសាលាសម្លេងម្ចាស់ឆ្នោតស្តីពី "**ការកំណត់តម្រូវការជាអាទិភាពនៅឃុំ-សង្កាត់ដាច់ស្រយាល**" ចំនួន១០ នៅតាមទីកន្លែងដោយឡែកៗពីគ្នា។

សិក្ខាសាលានេះមានគោលបំណង បង្កើនការយល់ដឹងដល់ម្ចាស់ឆ្នោតអំពី សិទ្ធិ តួនាទី និងកាតព្វកិច្ចរបស់ម្ចាស់ឆ្នោត ក្នុងការអភិវឌ្ឍន៍នៅមូលដ្ឋាន និងបង្កើនឱកាសឱ្យម្ចាស់ឆ្នោត ចូលរួមក្នុងការពិភាក្សាដើម្បីកំណត់តម្រូវការអាទិភាពក្នុងឃុំ-សង្កាត់របស់ខ្លួន ហើយតម្រូវការជាអាទិភាពទាំងនេះ នឹងត្រូវបានចងក្រងជារបាយការណ៍ដែលអាចឱ្យសិក្ខាកាមងាយចងចាំដើម្បីចូលរួមតាមដាន និងជម្រុញការអនុវត្តន៍របស់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងការដាក់បញ្ចូលតម្រូវការក្នុងកម្មវិធីនយោបាយរបស់គណបក្សក្នុងឃុំ។

ខុមហ្វ្រែល នឹងអញ្ជើញវាគ្មិនជាក្រុមប្រឹក្សាឃុំ-សង្កាត់ តំណាងគណបក្សនយោបាយក្នុងឃុំ-សង្កាត់ និងតំណាងអង្គការសង្គមស៊ីវិល ឬប្រធានសហគមន៍ដើម្បីចាប់អារម្មណ៍ទៅលើតម្រូវការជាអាទិភាពក្នុងឃុំ-សង្កាត់ដែលបានលើកឡើងដោយផ្ទាល់ពីប្រជាពលរដ្ឋនៅក្នុងឃុំសម្រាប់ផ្តល់ជូនគណបក្សនយោបាយ និងមន្ត្រីជាប់ឆ្នោតបំពេញ។

សេចក្តីជូនដំណឹងនេះ ចាត់ទុកជាការអញ្ជើញដល់លោក លោកស្រី នាងកញ្ញា តំណាងសារព័ត៌មាន វិទ្យុ ទូរទស្សន៍ជាតិ អន្តរជាតិ ព្រមទាំងអង្គការជាតិ និងអន្តរជាតិទាំងអស់ចូលរួមយកព័ត៌មានតាមការគួរ។

## ទីកន្លែង និងកាលបរិច្ឆេទ សិក្ខាសាលាសម្លេងម្ចាស់ឆ្នោត

| ល.រ | ថ្ងៃខែឆ្នាំរៀបចំ | ឃុំ/សង្កាត់ | ក្រុង/ស្រុក/ខណ្ឌ | រាជធានី/ខេត្ត | ឈ្មោះទំនាក់ទំនង | លេខទូរសព្ទ |
|---|---|---|---|---|---|---|
| ១ | ០៥/០៣/២០១២ | ប្រមេរ្ត | ត្បែងមានជ័យ | ព្រះវិហារ | **អ្នកស្រី លន់ ស៊ីថាន់** | **០១២ ៨៩១ ៦២៧** |
| ២ | ១២/០៣/២០១២ | រម្មណីយ៍ | រវៀង | | | |
| ៣ | ១៤/០៣/២០១២ | អង្គកែវ | ទ្រាំង | តាកែវ | **អ្នកស្រី សេខ សុឆ្នារី** | **០១២ ៨៩២ ៤៨៦** |
| ៤ | ១៧/០៣/២០១២ | សំអាង | ថាឡាបរិវ៉ាត់ | ស្ទឹងត្រែង | **លោក សុខ សុខ** | **០៩២ ៥៩០ ៦៨៦** |
| ៥ | ១៩/០៣/២០១២ | បាក់អណ្តូង | ត្រពាំងប្រាសាទ | ឧត្តរមានជ័យ | **លោក ចៅ ឌុទ្ធី** | **០១២ ៥៦៣ ៥៩៨** |
| ៦ | ១៩/០៣/២០១២ | ជីខក្រោម | ស្រែអំបិល | កោះកុង | **កញ្ញា ជា សុវណ្ណាលីន** | **០១៧ ៩១៥ ៥៩៣** |
| ៧ | ២១/០៣/២០១២ | ទំរីង | សណ្តាន់ | កំពង់ធំ | **អ្នកស្រី គន្ធ ស៊ីថា** | **០១២ ៩៦៧ ១៩៤** |
| ៨ | ២១/០២/២០១២ | កំពង់ឃ្លាំង | សូត្រនិគម | សៀមរាប | **លោក ផល ម៉ិនឥ** | **០៩២ ៦៧៦ ៩៨១** |

**ទីស្នាក់ការកណ្តាល** ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
**Central Office : #138, Street. 122, TeukLaak I, TuolKork, Phnom Penh, CAMBODIA.**
**P.O. Box**1145, **Phone** : (855) 23 884 150 **Fax**: (855) 23 885 745 **E-mail** : comfrel@online.com.kh **Website**: www.comfrel.org

| | | | | | | |
|---|---|---|---|---|---|---|
| ៩ | ២២/០៣/២០១២ | សំរោងសែន | កំពង់ឡែង | កំពង់ឆ្នាំង | **លោក លាប ម៉ិនលាង** | **០១២ ៣៤២ ៤១៧** |
| ១០ | ២៣/០៣/២០១២ | ស្វាយចចិប | បរសេដ្ឋ | កំពង់ស្ពឺ | **លោក ឡេង ពុទ្ធី** | **០១២ ៣៣១ ៦៤០** |

*សូមរក្សាសិទ្ធិកែប្រែក្នុងករណីចាំបាច់ !*

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០២ ខែមិនា ឆ្នាំ២០១២*

**ព័ត៌មានបន្ថែមសូមទំនាក់ទំនង ៖**

១- លោក **ម្លូង បឿត** (មន្ត្រីផ្នែកបណ្ដាញ និងវេទិកា)

ទូរស័ព្ទលេខ ៖ **(០១២ ៩៧១ ៣២៦)**

២- អ្នកស្រី **ហេង សុគន្ធា** (ជំនួយការផ្នែកបណ្ដាញ និងវេទិកា)

ទូរស័ព្ទលេខ ៖ **(០១៧ ៥៨៣ ៨៦៩)**

<u>**បេសកម្ម**</u> ៖ បេសកកម្មរបស់ខុមហ្វ្រែល គឺជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានពត៌មានគ្រប់គ្រាន់ ទី១/**ដើម្បីឱ្យមានដំណើរការបោះឆ្នោតដោយសេរី និងយុត្តិធម៌**តាមរយៈការបញ្ចុះបញ្ចូល តស៊ូមតិ ដើម្បីទទួលបាននូវក្របខ័ណច្បាប់សមរម្យ, ការអប់រំដើម្បីផ្ដល់ពត៌មានដល់អ្នកបោះឆ្នោតអំពីសិទ្ធិ និងសកម្មភាពចូលរួមសង្កេតការណ៍របស់ពួកគេ ដែលអាចរារាំងនូវភាពមិនប្រក្រតី ព្រមទាំងផ្ដល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឲ្យមានការវាយតម្លៃលើដំណើរការ បោះឆ្នោតមួយដែលមិនលំអៀង និងមិនប្រកាន់បក្សពួក ទី២/ **ដើម្បីឱ្យមានអត្ថន័យនៃដំណាក់កាលក្រោយពេលបោះឆ្នោត** តាមរយៈការអប់រំ និងវេទិកាសាធារណៈក្នុងគោលបំណងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមក្នុងកិច្ចការនយោបាយ និងការធ្វើសេចក្ដីសំរេចនានា ការតស៊ូមតិ/បញ្ចុះបញ្ចូលដើម្បីឱ្យមានការកែទម្រង់ ដំណើរការបោះឆ្នោតដែលបង្កើននូវគណនេយ្យភាព (ការទទួលខុសត្រូវ) របស់មន្ត្រីជាប់ឆ្នោត ព្រមទាំងផ្ដល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឱ្យមានការវាយតម្លៃមួយដែលមិនលំអៀង និងប្រកាន់បក្សពួកទៅលើការបំពេញកម្មវិធីនយោបាយ និងដំណើរការអនុវត្តន៍ការងាររបស់មន្ត្រីជាប់ឆ្នោត។